**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ / នស / ៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំ រេ ច

## ជំពូកទី ១

## អំពីការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា « ក.អ.ក » ដែលមានសមាសភាពដូចតទៅ ÷

១- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ប្រធាន

២- ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១

៣- ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធាន

៤- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង

៦- រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ឬតំណាង

៧- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង សមាជិក

៨- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតំណាង សមាជិក

៩- សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង សមាជិក

១០- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង សមាជិក

១១- រដ្ឋមន្ត្រីក្រសួងពត៌មាន ឬតំណាង សមាជិក

១២- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង សមាជិក

១៣- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង សមាជិក

១៤- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង សមាជិក

១៥- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង សមាជិក

១៦- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង សមាជិក

១៧- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង សមាជិក

១៨- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ឬតំណាង សមាជិក

១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឬតំណាង សមាជិក

២០- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង សមាជិក

២១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង សមាជិក

២២- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក

២៣- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង សមាជិក

២៤- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង សមាជិក

២៥- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក

២៦- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង សមាជិក

២៧- រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច ឬតំណាង សមាជិក

២៨- រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឬតំណាង សមាជិក

២៩- អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬតំណាង សមាជិក

៣០- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង សមាជិក

៣១- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬតំណាង សមាជិក

៣២- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ឬតំណាង សមាជិក

៣៣- អគ្គនាយកនគរបាលជាតិ ឬ តំណាង សមាជិក

៣៤- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឬតំណាង សមាជិក

៣៥- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៣៦- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ សមាជិក

៣៧- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

៣៨- អភិបាលខេត្ត- ក្រុង ឬ តំណាង សមាជិក

៣៩- ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឬតំណាង សមាជិក

**មាត្រា ២** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ហៅកាត់ «គ.ជ.ទា» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ « គ.វ.ក» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៣- អគ្គលេខាធិការដ្ឋាននៃ «ក.អ.ក » ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ « ក.អ.ក » ។ អគ្គលេខាធិការដ្ឋាននេះរួមមាន «ផ្នែកគាំទ្រ » ចំនួន ៤ ÷

- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល
- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក
- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ ។

**មាត្រា ៣** : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងអគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានអគ្គលេខាធិការរងមួយរូបៗរៀងៗខ្លួនសំរាប់ជាជំនួយការក្នុងការងារ ។ អគ្គលេខាធិការរងនីមួយៗបំពេញកិច្ចការតាមភារកិច្ចដែលអគ្គលេខាធិការប្រគល់អោយក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ។ អគ្គលេខាធិការមួយរូបៗ ត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន ។

**មាត្រា ៤** : គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ អូសទាញ និងសំរបសំរួលជំនួយ

២- ផ្នែកឯកសារ និងគ្រប់គ្រងពត៌មាន

៣- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ÷

- ជប៉ុន និងអាស៊ី
- បារាំង និងអឺរ៉ុប
- អូស្ត្រាលី និងអូសេអានី
- សហរដ្ឋអាមេរិក

៤- ផ្នែកគ្រប់គ្រងជំនួយពហុភាគី ÷

- ធនាគារអភិវឌ្ឍន៍អាស៊ី

- ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
- សហគមន៍អឺរ៉ុប

៥- ផ្នែកគ្រប់គ្រងជំនួយរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិនិងបណ្តាអង្គការរបស់សហប្រជាជាតិ

៦- ផ្នែកសំរបសំរួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៧- ផ្នែកវិភាគគំរោង

៨- ផ្នែករដ្ឋបាល ។

**មាត្រា ៥** : គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកការគ្រប់គ្រងពត៌មាន និងឯកសារ

២- ផ្នែកទំនាក់ទំនងសាធារណៈ និងការជំរុញគំរោងវិនិយោគឯកជន

៣- ផ្នែកវិភាគគំរោង និងការលើកទឹកចិត្ត

៤- ផ្នែកវាយតំលៃខាងបរិស្ថាន

៥- ផ្នែកសំរបសំរួលកិច្ចការអន្តរក្រសួង

៦- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៧- ផ្នែកនីតិវិធី និងច្បាប់វិនិយោគ

៨- ផ្នែករដ្ឋបាល ។

**មាត្រា ៦** : ផ្នែកនិងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូបជាជំនួយការ ។

**មាត្រា ៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ ÷

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ។

## ជំពូកទី ២

## អំពីសមត្ថកិច្ច និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ៨** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានសមត្ថកិច្ចដូចតទៅ ÷

១- ជាសេនាធិការ និងជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

២- ដឹកនាំការងាររៀបចំទស្សនទាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់ប្រទេសកម្ពុជា ដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ។

៣- ទាក់ទងជាមួយប្រទេស អង្គការអន្តរជាតិពហុភាគី/ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើអោយគេយល់ដឹងជ្រាបអំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃកម្មវិធីជាតិសំរាប់នីតិសម្បទា និអភិវឌ្ឍន៍ប្រទេស ដើម្បីសំរបសំរួលការទទួល និងការប្រើប្រាស់ជំនួយអន្តរជាតិអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ។

៤- សំរបសំរួលការងាររវាងបណ្តាក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធ និងសំរបសំរួលការងាររវាងបណ្តាក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយ ព្រមទាំងជាមួយអ្នកវិនិយោគ ។

៥- តំរង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

៦- បង្កលក្ខណៈងាយស្រួល និងសំរួលកិច្ចការដល់អ្នកផ្តល់ជំនួយ និងដល់អ្នកវិនិយោគ ។

៧- ពិនិត្យ និងសំរេចរាល់កិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ » នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៩** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់ពីគណៈរដ្ឋមន្ត្រី លើគំរោងវិនិយោគទាំងឡាយ ដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ ÷

១- ទុំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គំរោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គំរោង «សង់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស.អ.ផ» ឬ គំរោង «សង់-កាន់កាប់-អាជីវកម្ម-ផ្ទេរ» ហៅ កាត់ «ស.ក.អ.ផ» ឬ គំរោង «សង់-កាន់កាប់-អាជីវកម្ម» ហៅកាត់ «ស.ក.អ» ឬ គំរោង «សង់- ជួល-ផ្ទេរ» ហៅកាត់ «ស.ជ.ផ» ។

**មាត្រា ១០** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន ។

**មាត្រា ១១** : ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំទស្សនទានជាយុទ្ធសាស្ត្រសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស និងដើម្បីលើកឡើងនូវលំដាប់អាទិភាព នៃ[illegible]របស់ប្រទេសជាតិ ក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងសំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង

ដើម្បីបង្កើតឡើងនូវកម្មវិធីការងាររំកិលតាមឆ្នាំ ។ កម្មវិធីនេះ ត្រូវមានលក្ខណៈជាប្រព័ន្ធរលូន ប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ។

២- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និង ផែនការតាមផ្នែកសំរាប់អភិវឌ្ឍន៍កម្ពុជា ។

៣- គ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័ន ទាំងឡាយដែលមានការពាក់ព័ន្ធ ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសំរបសំរួល និងការតំរង់ ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេសនិងធនធានដែលបានមកពីក្រៅ ប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

៤- ធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងរាជរដ្ឋាភិបាលជាមួយ នឹងប្រទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាអ្នកផ្តល់ជំនួយដល់ កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងក្រសួង និង ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលការទទួលជំនួយ និង/ឬ ការបែងចែកជំនួយ ។

៥- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងអ្នកផ្តល់ ជំនួយទ្វេភាគីពហុភាគី និង/ឬ អង្គការអន្តរជាតិនានា ដើម្បីទទួលជំនួយនិង/ឬ បែងចែកជំនួយ ។

៦- សហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធដឹកនាំការងារ ក្នុងការរៀបចំ ឯកសារចាំបាច់នានាសំរាប់កិច្ចប្រជុំអន្តរជាតិ សំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ដូចជា «ក្រុមពិគ្រោះយោបល់សំរាប់កម្ពុជា» ជាដើម ។

៧- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគសាធារណៈ សំរាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និង លើកឡើង នូវវិធានការចាំបាច់សំរាប់កែលំអ និងតំរង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍ ។

**មាត្រា ១២** : ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ ÷

១- «ក.អ.ក» ជាអ្នកសំរបសំរួលក្នុងការលើកទស្សនទានជាយុទ្ធសាស្ត្រ និងគោលនយោបាយនៃកិច្ច ការវិនិយោគសាធារណៈ ព្រមទាំងជាអ្នកសំរបសំរួល ក្នុងការកំណត់ លំដាប់អាទិភាពនៃកម្មវិធី និង គំរោងវិនិយោគសាធារណៈសំរាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្គួចការទូតផ្លូវការ ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នករៀបចំផែនការ ៥ ឆ្នាំ និងក្នុងវិស័យ វិនិយោគសាធារណៈ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នករៀបចំការប៉ាន់ស្មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសំរាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ។

៥- ក្រសួងជំនាញ ជាអ្នករៀបចំកម្មវិធី និងគំរោងការវិនិយោគសាធារណៈតាមផ្នែក ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ « ក.អ.ក » ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគំរោងការវិនិយោគសាធារណៈតាមផ្នែក ដែលមានការពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន ។

**មាត្រា ១៣** : ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួនខាងវិនិយោគសាធារណៈដោយសំរបសំរួលការងារជាមួយគ្នាតាមរយៈយន្តការ « ច្រកចេញចូលតែមួយ » ។

**មាត្រា ១៤** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តន៍កម្មវិធី និង/ឬ គំរោង ស្របតាមសមត្ថកិច្ចរៀងៗខ្លួន ដោយសំរបសំរួលការងារជាមួយគ្នា តាមរយៈយន្តការ « ច្រកចេញចូលតែមួយ » ។

**មាត្រា ១៥** : ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ « ច្រកចេញចូលតែមួយ » និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសំរេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ « ការប្រណាំងប្រជែងដណ្តើមឈ្នះ » លើទីផ្សារអន្តរជាតិសំរាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសំរាប់ប្រទេសកម្ពុជា និងសំរេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជា « សាជីវកម្មកម្ពុជា » ។ សហការជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគំរោងនានាសំរាប់ការវិនិយោគឯកជន ។

៣- ផ្សព្វផ្សាយអំពីគំរោងនានាសំរាប់ការវិនិយោគឯកជនដែលរាជរដ្ឋាភិបាលបានលើកឡើងនិងផ្តល់គំរោងទាំងនោះទៅអោយអ្នកវិនិយោគតាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ញត្តិផ្ទៃក្នុង នៃ « ក.អ.ក » ។

៤- សំរបសំរួលការគ្រប់គ្រងគំរោង «សង់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស-អ-ផ» គំរោង «សង់-កាន់កាប់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស-ក-អ-ផ» គំរោង «សង់-កាន់កាប់-អាជីវកម្ម» ហៅកាត់ «ស-ក-អ» និងគំរោង «សង់-ជួល-ផ្ទេរ» ហៅកាត់ «ស-ជ-ផ» ។

៥- ផ្តួចផ្តើម និងសំរបសំរួលការគ្រប់គ្រងតំបន់អភិវឌ្ឍន៍ពិសេស ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ។

៦- លើកគំរោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗដែលទាក់ទិនទៅនឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌ

ដែលអន្តរាគមន៍ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន ។

៧- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសំរាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់កែលំអ និងតំរង់ទិសការងារវិនិយោគឯកជន ។

**មាត្រា ១៦** : ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ ÷

១- «ក.អ.ក» បំពេញតួនាទីជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជននានា ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ដូចមានកំណត់នៅក្នុងមាត្រា ២៩ ។

**មាត្រា ១៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសំរបសំរួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៨** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬ ស្ថាប័ន ដែលមានការពាក់ព័ន្ធ ជាអ្នកតាមដានការអនុវត្តន៍គំរោងវិនិយោគឯកជន ដែល «ក.អ.ក» បានផ្តល់ការអនុញ្ញាតហើយ ដោយសំរបសំរួលការងារជាមួយគ្នាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

## ជំពូកទី ៣

## ការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១៩** : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ :

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក» ។

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៣- ដឹកនាំពិភាក្សានិងថែរក្សាសណ្តាប់ធ្នាប់ នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងអង្គប្រជុំពេញអង្គ «ក.អ.ក» ។

៤- ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងអង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៥- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងប្រជុំវិសាមញ្ញ ពេញអង្គរបស់ «ក.អ.ក» ។

៦- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ «ក.អ.ក» ។

**មាត្រា ២០** : អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ :

**ក**- ឯកឧត្តម **គាត ឈន់** អនុប្រធានទី ១ ÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក» ក្នុងករណីដែល ប្រធាន «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជារួម ។

៣- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការរបស់នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតជាសំខាន់ទៅលើការសំរបសំរួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការគៀងគរ និងសំរបសំរួលជំនួយបរទេស ។

៤- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ «ក.អ.ក» ។

៥- ធ្វើជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» និងចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំនោះ ក្នុងករណីដែលប្រធាន «ក.អ.ក» អវត្តមាន ។

៦- ទទួលបន្ទុកក្នុងការសំរបសំរួលការងារអន្តរក្រសួងរវាង «ក.អ.ក» ជាមួយនឹងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល ។

៧- ទទួលបន្ទុកក្នុងការទាក់ទងជាមួយប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយនានា ។

៨- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើង ដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការងារវិនិយោគនានា មុននឹងដាក់ស្នើសុំសេចក្តីសំរេចពីអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ។

៩- បំពេញការងារដទៃទៀតដែលប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**ខ**- ឯកឧត្តម **ចម ប្រសិទ្ធ** អនុប្រធាន ÷

១- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលប្រធាន និងអនុប្រធានទី១ នៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន និងកិច្ចការដឹកនាំអនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និង

យុទ្ធសាស្ត្រនេះ ដោយរាប់បញ្ចូលទាំងការរៀបចំតំបន់ពាណិជ្ជកម្មសេរី តំបន់កែច្នៃសំរាប់ការនាំចេញ និងតំបន់ឧស្សាហកម្មពិសេសផ្សេងៗទៀត ។

៣- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន ។

៤- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ។

៥- បំពេញការងារដទៃទៀតដែលប្រធាន « ក.អ.ក » ប្រគល់សិទ្ធិ ។

**គ**- ឯកឧត្តម **គង់ ទិបុល** អនុប្រធាន ÷

១- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក » ក្នុងករណីដែលប្រធាន និងអនុប្រធានទាំងពីររូបនៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកការងារប្រចាំរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក » ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ក្នុងករណីឯកឧត្តម ចម ប្រសិទ្ធ អវត្តមាន ឬជាប់រវល់ដោយប្រការណាមួយ ។

៤- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសំរបសំរួលជាមួយអនុប្រធានពីររូបទៀត ។

៥- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលប្រធាន និងអនុប្រធានពីររូបទៀតនៃ «ក.អ.ក» អវត្តមាន ។

៦- បំពេញការងារដទៃទៀតដែលប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២១** : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- ទទួលបន្ទុកក្នុងការសំរបសំរួល និងតាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងគណៈកម្មាធិការវិនិយោគកម្ពុជា ព្រមទាំងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ«ក.អ.ក»។

២- ធ្វើជាសេនាធិការបច្ចេកទេសអោយ «ក.អ.ក» ក្នុងការដឹកនាំអនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ ពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន ។

៣- រៀបចំកម្មវិធីការងាររបស់ «ក.អ.ក» និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងសំរាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- រៀបចំកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងនៃអង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ដើម្បីដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខា ។

៥- រៀបចំសេចក្តីប្រកាសពត៌មានរបស់ « ក.អ.ក » ។

៦- ជួយសំរបសំរួលការរៀបចំរបាយការណ៍ប្រចាំខែមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៧- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា ។

៨- បំពេញការងារដទៃទៀត ដែលប្រធាន «ក.អ.ក» ឬ អនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

៩- ទទួលបន្ទុកជាអគ្គលេខាធិការនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ។

**មាត្រា ២២** : អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ « គ.ជ.នា » ។

២- រៀបចំរបៀបវារៈ និងឯកសារសំរាប់អង្គប្រជុំនយន្តការ «ច្រកចេញចូលតែមួយ »ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និងសំរាប់អង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ។

៤- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ដើម្បីពិនិត្យ និងចាត់វិធានការណ៍កែតំរូវក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំខែមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ស្របតាមការប្រគល់ភារកិច្ចពីប្រធាន «ក.អ.ក » ឬ អនុប្រធាន «ក.អ.ក » ប្រគល់សិទ្ធិ ។

**មាត្រា ២៣** : អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ « គ.វ.ក »

២- រៀបចំរបៀបវារៈ និងឯកសារសំរាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន ។

៣- ជួយដល់អគ្គលេខាធិការ « ក.អ.ក » ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និងសំរាប់អង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ។

៤- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ដើម្បីពិនិត្យនិងចាត់វិធានការកែតំរូវក្នុងករណីចាំបាច់

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក » ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន « ក.អ.ក » ពិនិត្យ និងអនុម័តមុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេចលើកិច្ចការវិនិយោគឯកជន ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ស្របតាមការប្រគល់ភារកិច្ចពីប្រធាន ឬ អនុប្រធាន « ក.អ.ក » ប្រគល់សិទ្ធិ ។

**មាត្រា ២៤** : សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគំរោងវិនិយោគនានា ទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន ។

២- ចូលរួមក្នុងការត្រួតពិនិត្យ ការអនុវត្តន៍គោលនយោបាយកម្មវិធី និងគំរោងវិនិយោគនានា ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័ត ទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន ។

៣- ពិនិត្យ និងអនុម័ត របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**មាត្រា ២៥** : គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ត្រូវអញ្ជើញចូលរួមប្រជុំក្នុងពីរអាទិត្យម្តង ។

**មាត្រា ២៦** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកោះប្រជុំពេញអង្គក្នុងមួយខែម្តង ។

**មាត្រា ២៧** : ក្នុងករណីចាំបាច់ ប្រធាន « ក.អ.ក » អាចនឹងកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ឬ ប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក» ។

**មាត្រា ២៨**: ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក » និងអង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក » ។

**មាត្រា ២៩:** ការអនុវត្តន៍ការងារនៃយន្តការ «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ ដូចខាងក្រោម ÷

ទី១- សំរាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ÷

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាន ឬ អនុប្រធាននាយកដ្ឋានមួយរូប អោយមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។ មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្ថិតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ « ច្រកចេញចូលតែមួយ » នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ « អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.ជ.នា » ចំពោះតែកិច្ចការវិនិយោគសាធារណៈណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង ស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ «គ.ជ.នា » មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃស្ថាប័ន «ច្រកចេញចូលតែមួយ » ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុតាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ តំរោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេច ។

ង- អគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ « ក.អ.ក » ពិនិត្យ និងសំរេច ។

ទី២- សំរាប់គណៈកម្មាធិកាវិនិយោគកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងពន្ធនាគារ និង... ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់

ប្រធាន ឬ អនុប្រធានាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការវិនិយោគកម្ពុជា ។ មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមជំនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរម្ចតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្ថិតរម្ចតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃទៀត នៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងសំរាប់ចូលរួមក្នុងយន្តការ « ច្រកចេញចូលតែមួយ » នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ « អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.វ.ក » ចំពោះតែគំរោងការវិនិយោគឯកជនណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ «គ.វ.ក» មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសំរេចក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ» ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាពេញលេញសព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ «គ.វ.ក» ត្រូវរៀបចំបញ្ចូលរបៀបវារៈ ឬគំរោងនោះ ទៅក្នុងអង្គប្រជុំ នៃយន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសំរេច ។

ង- អគ្គលេខាធិការ «គ.វ.ក» ត្រូវរៀបចំសំណុំឯកសារ និងវាកិតិមានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ» បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ « ក.អ.ក» ពិនិត្យ និងសំរេច ។

ទី៣- ក្រោយពីបានទទួលគ្រប់គ្រាន់នូវឯកសារ និងពតិមានផ្សេងៗ ពីអគ្គលេខាធិការ «គ.ជ.ទ» និងអគ្គលេខាធិការ «គ.វ.ក » មក អគ្គលេខាធិការ «ក.អ.ក » ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ «ក.អ.ក» ដើម្បីពិនិត្យ និងសំរេច ។

**មាត្រា ៣០** : សេចក្តីលំអិតអំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃស្ថាប័ន «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក» ។

**មាត្រា ៣១** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការនិងមានខ្ទង់ចំណូលនិងចំណាយថវិកាដាច់ដោយឡែក។ ការគ្រប់គ្រងចំណូលនិងចំណាយថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣២** : អនុក្រឹត្យលេខ ៥១ / អនក្រ.បក / ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ និងអនុក្រឹត្យលេខ ៤៨ / អនក្រ.បក / ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១*

ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

<u>ចម្លងជូន</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣៣*
- *កាលប្បវត្តិ-ឯកសារ*